ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 08 / 2012
ម៉ោង (Time/Heure): 15:25
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ព្រហស្បត្តិ៍ ទី ០៩ ខែ សីហា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៩៣

រៀបចំដោយ: សែ កុលវុឌ្ឍី និង Matteo CRIPPA

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោកស្រី សែ កុលវុឌ្ឍី, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក ច័ន្ទ ដារាវរស្មី, លោក Vincent DE WILDE D'ESTMAEL, លោក Dale LYSAK |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោម), នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KANAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta Guisse |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក Ferdinand Djammen Nzepa, លោកស្រី ជេត វណ្ណលី, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី Marie GUIRAUD. |
| សាក្សី៖ អ៊ុង ចុងហៀង (TCW-490) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Eleanor DOYLE-MARKWICK |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.២០ | បញ្ចប់ម៉ោង៖ ១០.៤០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៥០ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ០៩.០៥<br>១២.០២ | ០៩.០៨<br>១២.០២ |
| ការបន្តតាំងសំណួរទៅសាក្សី អ៊ុង ចុងហៀង (TCW-490) | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួនជា<br>មេធាវីការពារក្តី អៀង សារី | ០៩.០៨<br>១១.២៤<br>១៣.៤៤<br>១៥.២៤ | ១១.២៤<br>១២.០០<br>១៥.២៤<br>១៦.០៣ |
| ការកត់សម្គាល់អំពីការបញ្ចេញអារម្មណ៍របស់សាក្សីក្នុងអំឡុងពេលដំណើរការនីតិវិធី | មេធាវីការពារក្តី អៀង សារី | ១៣.៣២ | ១៣.៤៣ |
| ការជំទាស់ចំពោះការតាំងសំណួរក្រៅអង្គ | សហព្រះរាជអាជ្ញា | ១៤.១០ | ១៤.១៥ |

| ហេតុ | | | |
|---|---|---|---|

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ (ជនជាប់ចោទ អៀង សារី សម្រាប់រយៈពេលមួយថ្ងៃ ហើយជនជាប់ចោទ នួន ជា សម្រាប់សវនាការពេលរសៀល) ។

**ការតាំងសំណួរទៅសាក្សី អ៊ុង ឆុងហឿង** (TCW-490)

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី អៀង សារី បានតាំងសំណួរទៅសាក្សី អ៊ុង ឆុងហឿង។

**ការកត់សម្គាល់អំពីការបញ្ចេញអារម្មណ៍របស់សាក្សីក្នុងអំឡុងពេលដំណើរការនីតិវិធី**

មេធាវីការពារក្តី អៀង សារី បានធ្វើការកត់សម្គាល់ទៅលើការបញ្ចេញអារម្មណ៍របស់សាក្សីក្នុងពេលឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានឆ្លើយតបចំពោះការកត់សម្គាល់នេះថា មេធាវីអាចធ្វើការជំទាស់ទៅនឹងការតាំងសំណួរណាមួយ នៅពេលដែលភាគីកំពុងតែចោទសួរទៅសាក្សី ហើយមេធាវីមិនត្រូវធ្វើឱ្យសាក្សីបាត់ទំនុកចិត្តក្នុងការផ្តល់ភស្តុតាងដល់អង្គជំនុំជម្រះឡើយ។

**ការជំទាស់ចំពោះការតាំងសំណួរក្រៅអង្គហេតុ**

សហព្រះរាជអាជ្ញាបានជំទាស់ចំពោះការតាំងសំណួរទៅសាក្សីទាក់ទងនឹងអង្គហេតុដែលស្ថិតនៅក្រៅវិសាលភាពនៃអង្គហេតុដែលកំពុងជម្រះនៅពេលនេះ។ អង្គជំនុំជម្រះបានទទួលយកការជំទាស់ ប៉ុន្តែមេធាវីការពារក្តី នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចដោយមានសម្អាងហេតុជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះបានបដិសេធចំពោះសំណើសុំនេះ និងបានជូនដំណឹងទៅមេធាវីថា មេធាវីមិនមានសិទ្ធិក្នុងការផ្តល់មតិយោបល់ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនោះទេ មេធាវីមានសិទ្ធិក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះបានផ្អែកទៅតាមវិធានផ្ទៃក្នុង។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/97 | D141/1 | 00270680-00270707 00287097-00287112 00241881-00241896 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អុង ថុងហឿង [Surrogate Sheet] Written Record of Interview of ONG Thong Hoeung [Feuille remplacée] Procès verbal d'audition de ONG Thong Hoeung | P | 00270685, 00270705, 00270684-00270686 | 00287100, 00297110, | 00241884, 00241883-00241884 |
| E3/1713 | D141/1.2 | 00659077-00659085, 00831062-00831320 00785742-00785882, 00657418-00657425 00287879-00288154 | ឧបសម្ព័ន្ធ ២៖ សៀវភៅនិពន្ធដោយលោក អុង ថុងហឿង មានចំណងជើងថា "ត្រលប់មើលក្រោយវិញនៃរឿងដ៏សែនខ្លោចផ្សាមួយ" [Partial T.] Annex 2: Book by ONG Thong Hoeung entitled "J'ai cru aux Khmers rouges: Retour sur une illusion" Annexe 2: Livre écrit par ONG Thong Hoeung intitulé "J'ai cru aux Khmers rouges: Retour sur une illusion" | P | 00659078, 00831246, 00831254, 00831070, 00659077-00659085, 00831241, 00831253-00831254, 00831255 | 00657419, 00785878-79 | 00287879-00288154, 00288092, 00288100, 00288019, 00288093 -94, 00288086, 00288101, 00288102 |
| E3/1714 | D108/27.19 | 00324672-00324798 00170692-00170773 00648960-00649033 | ឧបសម្ព័ន្ធ១៩៖ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ Annex 19: Interviews with Kampuchean Refugees at Thai-Cambodia Border, Prepared for the Ishiyama Committee Annual Report, 1980 Annex 19: Rapport annuel: Auditions de refugiés kampuchéens à la frontière thailandaise, préparées pour le comité Ishiyama, 1980 | P | | | |
| E3/1683 | D108/50/1.75 | 00701668-00701679, 00820987-00820997, 00823678-00823691, 00825418-00825422 00193067-00193488 00824485-00824491, 00726657-00726663, 00825423-00825430 | [Partial T.] ឧបសម្ព័ន្ធ ៧៥៖ សៀវភៅមានចំណងជើងថា សោកនាដកម្មជាប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា Annex 75: Book entitled "The Tragedy of Cambodian History" [Partial T.] Annexe 75: Livre de David P. Chandler "The Tragedy of Cambodian History, Politics, War and Revolution since 1945"- Extraits | P | | 00193374 | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី (០៩.០៥) និង នួន ជា (១២.០២) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សម្របសម្រួលដល់ សាក្សី អ៊ុង ចុងហឿង ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងឲ្យនាំគាត់មកកាន់បន្ទប់សវនាការវិញនៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២។

| **កាលបរិច្ឆេទបន្តសវនាការ៖** |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ ច័ន្ទ ទី ១៣ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ កុលទន្សា Matteo CRIPPA